**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យាដើម្បីចូលបម្រើការងារ នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមជម្រាបជូនដំណឹង ដល់សាធារណជនឱ្យបានជ្រាបថា ក្រសួងសេដ្ឋកិច្ច-និងហិរញ្ញវត្ថុ ត្រូវការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យាសរុបចំនួន ១២ រូប មកបម្រើការងារពេញម៉ោងក្នុងតំណែងដូចខាងក្រោម៖

- បុគ្គលិកអភិវឌ្ឍអ៊ិនធឺណិតផ្នែកខាងមុខ (Front-End Developr) ចំនួន ២ រូប
- បុគ្គលិកអភិវឌ្ឍកម្មវិធីអ៊ិនធឺណិតផ្នែកខាងក្រោយ (Backend Developer) ចំនួន ៤ រូប
- បុគ្គលិកផ្នែកវិស្វករគ្រប់គ្រងគុណភាព (Quality Assurance Engineer) ចំនួន ៤ រូប
- បុគ្គលិកផ្នែកអភិវឌ្ឍបណ្តាញកម្មវិធីទូរស័ព្ទ (Cross Platform Mobile App Developer) ចំនួន ២ រូប

បេក្ខជនដែលនឹងត្រូវបានជ្រើសរើស នឹងទទួលបានប្រាក់បៀវត្សមូលដ្ឋានសមរម្យ ទៅតាមតួនាទីការងារ និង គុណវុឌ្ឍិ។ បេក្ខជនត្រូវចូលទៅកាន់ផតថល https://career.digitaleconomy.gov.kh/ រួចស្កែន QR Code ដែលមាននៅលើផតថលដោយប្រើប្រាស់កម្មវិធីទូរស័ព្ទ CamDigiKey ដើម្បីដាក់ពាក្យស្នើសុំបម្រើការងារ។ មានតែបេក្ខជនដែលជាប់ដំណាក់កាលសម្រាំងជ្រើសរើស (Shortlist) នឹងបន្តទៅកាន់វគ្គសម្ភាសន៍ផ្ទាល់មាត់។

ការទទួលពាក្យចាប់ផ្តើមពីថ្ងៃជូនដំណឹងនេះរហូតដល់ **ថ្ងៃទី២៩ ខែមិនា ឆ្នាំ ២០២៤ វេលាម៉ោង ១៧:00 នាទី។**

ថ្ងៃព្រហស្បតិ៍ ៥កើត ខែ ផល្គុន ឆ្នាំ ថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែ មិនា ឆ្នាំ ២០២៤

សូមស្កេនដើម្បីទៅកាន់ផតថល

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# លក្ខខណ្ឌយោង
## ស្តីពី
## ការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យាចំនួន ១២ រូប
## ដើម្បីចូលបម្រើការងារនៅ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*បេក្ខជន ត្រូវមានគុណវុឌ្ឍិទូទៅដូចខាងក្រោម៖*

- មានសញ្ញាបត្រកម្រិតបរិញ្ញាបត្រ ឬ សញ្ញាបត្រប្រហាក់ប្រហែលឡើងទៅស្របតាមតំណែងដែលបានជ្រើសរើស
- មានចំណេះដឹងភាសាអង់គ្លេសច្បាស់លាស់, អាចនិយាយ និង សរសេរជាផ្លូវការបាន
- មានសមត្ថភាពបំពេញការងារដោយឯករាជ្យ និង ជាក្រុមបានល្អក្នុងស្មារតីទទួលខុសត្រូវខ្ពស់
- មានគំនិតផ្តួចផ្តើម, សមត្ថភាពគ្រប់គ្រង និង ដោះស្រាយការងារចាំបាច់បន្ទាន់ក្នុងពេលតែមួយ ប្រកបដោយភាពច្នៃប្រឌិត, ប្រសិទ្ធភាពខ្ពស់ និង ប្រកាន់ខ្ជាប់ស្មារតីបុរេសកម្ម
- មានអត្តចរិតស្លូតបូត, ស្មោះត្រង់, អត់ធ្មត់, ឧស្សាហ៍ព្យាយាម និងយកចិត្តទុកដាក់បំពេញការងារ
- មានអាកប្បកិរិយាល្អ, គោរពក្រមសីលធម៌វិជ្ជាជីវៈ និង ពុំមានជាប់ទោសពីបទឧក្រិដ្ឋ ឬ មជ្ឈិម
- មានឆន្ទៈខ្ពស់ក្នុងការចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការកសាង និង អភិវឌ្ឍសេដ្ឋកិច្ច, ធុរកិច្ច និងសង្គមឌីជីថល។

## ១. បុគ្គលិកអភិវឌ្ឍកម្មវិធីអ៊ីនធឺណិតផ្នែកខាងមុខ (Front-End Developer)

*ភារកិច្ច និង ការទទួលខុសត្រូវ៖*

- ចូលរួមបំពេញការងារគ្រប់ដំណាក់កាលនៃវដ្តគម្រោង (Agile Project Cycle) រួមមាន៖ ការរចនា, ការបង្កើតគំរូ, ការអភិវឌ្ឍន៍, និងការធ្វើតេស្តសាកល្បង តាមរយៈការប្រើប្រាស់កម្មវិធីគ្រប់គ្រងគម្រោង និងប្រើប្រាស់បច្ចេកវិទ្យាចុងក្រោយ
- កែសម្រួលការរចនា និង Wireframes ឱ្យក្លាយទៅជាកូដដែលមានគុណភាពខ្ពស់
- កែសម្រួលកម្មវិធី ដើម្បីពង្រឹងការចូលគណនី (logging) ដោះស្រាយបញ្ហានានា និងដើម្បីពង្រឹងសុវត្ថិភាព និង ប្រតិបត្តិការរបស់ការងារ
- សហការជាមួយក្រុមការងារអភិវឌ្ឍកម្មវិធី ដើម្បីពន្លឿនដំណើរការនៃការអភិវឌ្ឍន៍សុសវែរ (Agile)
- រៀបចំយន្តការត្រួតពិនិត្យ និងធ្វើតេស្តសាកល្បងលើប្រព័ន្ធបច្ចេកវិទ្យាឌីជីថលមុននឹងដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ដើម្បីវាយតម្លៃអំពីហានិភ័យ, ផលប៉ះពាល់នៃប្រព័ន្ធទាំងមូល

- ជួបប្រជុំជាមួយអ្នកពាក់ព័ន្ធដើម្បីប្រមូលតម្រូវការ និង កំណត់វិសាលភាព
- កែលម្អផ្ទាំងកម្មវិធីអ៊ិនធឺណិតផ្នែកខាងមុខដើម្បីងាយស្រួលប្រើប្រាស់
- ធ្វើការស្រាវជ្រាវជាប្រចាំនូវការវិវឌ្ឍនៃបច្ចេកវិទ្យា និង ចំណេះដឹងថ្មីសម្រាប់អភិវឌ្ឍកម្មវិធីអ៊ិនធឺណិតផ្នែកខាងមុខ

*គុណវុឌ្ឍិ៖*

- មានបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ ផ្នែកបច្ចេកវិទ្យាព័ត៌មាន ឬ ជំនាញផ្សេងៗដែលពាក់ព័ន្ធ
- មានបទពិសោធន៍ក្នុងការអភិវឌ្ឍផ្ទាំងកម្មវិធីអ៊ិនធឺណិតផ្នែកខាងមុខ ឬ Platform យ៉ាងតិច ១ឆ្នាំ
- មានជំនាញភាសាកម្មវិធី និង បច្ចេកវិទ្យាអភិវឌ្ឍផ្ទាំងកម្មវិធីអ៊ិនធឺណិតផ្នែកខាងមុខ រួមទាំង HTML, CSS និង JavaScript
- មានចំណេះដឹងលើផ្នែក MVC, Design Patterns, Software architectures
- មានចំណេះដឹងលើផ្នែកសុវត្ថិភាពសម្រាប់អ៊ិនធឺណិត (ជាការប្រសើរ)
- មានបទពិសោធន៍លើការងារអភិវឌ្ឍកម្មវិធីអ៊ិនធឺណិតផ្នែកខាងមុខ React, Vue, Angular
- មានបទពិសោធន៍លើការងារអភិវឌ្ឍកម្មវិធីអ៊ិនធឺណិតផ្នែកខាងមុខដូចជា React, Vue, និង Angular
- មានបទពិសោធន៍ រៀបចំប្រព័ន្ធបណ្ដាញទំនាក់ទំនងជាមួយ Restful APIs
- មានសមត្ថភាពក្នុងការដោះស្រាយបញ្ហាសុសវែរ (Troubleshooting) ដោយឯករាជ្យ
- មានចំណេះដឹងភាសាខ្មែរ និង អង់គ្លេសច្បាស់លាស់ អាចនិយាយ និងសរសេរជាផ្លូវការបាន។

## ២. បុគ្គលិកអភិវឌ្ឍកម្មវិធីអ៊ិនធឺណិតផ្នែកខាងក្រោយ (Backend Developer)

*ភារកិច្ច និង ការទទួលខុសត្រូវ៖*

- ចូលរួមបំពេញការងារគ្រប់ដំណាក់កាលនៃវដ្តគម្រោង (Agile Project Cycle) រួមមានការរចនា ការបង្កើតគំរូ ការអភិវឌ្ឍន៍ និងការធ្វើតេស្តសាកល្បង តាមរយៈការប្រើប្រាស់កម្មវិធីគ្រប់គ្រងគម្រោង និងប្រើប្រាស់បច្ចេកវិទ្យាចុងក្រោយបំផុត។
- ធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (System Architecture) ដែលអាចសមាហរណកម្មជាមួយសេវាផ្សេងៗ និងសន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ (APIs)
- កែសម្រួលកម្មវិធី ដើម្បីពង្រឹងការចូលគណនី (logging) ដោះស្រាយបញ្ហានានា និងដើម្បីពង្រឹងសុវត្ថិភាព និង ប្រតិបត្តិការរបស់ការងារ
- សម្របសម្រួល ផែនការធ្វើតេស្ត (Test Plan) និង ការបំពេញលក្ខខណ្ឌតម្រូវផ្សេងៗ
- សហការជាមួយក្រុមការងារអភិវឌ្ឍកម្មវិធី ដើម្បីធ្វើតេស្តនៅពេលដែលផលិតផល ឬ សេវាកម្មឌីជីថល (Platform) បានដាក់ឱ្យប្រើប្រាស់
- ស្វែងយល់ និងស្រាវជ្រាវអំពីនិន្នាការវិវត្តថ្មីៗនៃបច្ចេកវិទ្យា

*គុណវុឌ្ឍិ៖*

- មានបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ ផ្នែកបច្ចេកវិទ្យាព័ត៌មាន ឬ ជំនាញដែលពាក់ព័ន្ធ
- មានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ (ជាការប្រសើរ)

- មានបទពិសោធន៍ក្នុងការអភិវឌ្ឍផ្នាំងកម្មវិធីអ៊ិនធឺណិតផ្នែកខាងក្រោយយ៉ាងតិច ១ឆ្នាំ
- មានបទពិសោធន៍ជាមួយ Structured និង None-Structured databases
- មានបទពិសោធន៍ជាមួយ Spring Boot framework ( ជាការប្រសើរ )
- មានបទពិសោធន៍ជាមួយការអនុវត្ត Micro-Services ( ជាការប្រសើរ )
- មានចំណេះដឹងលើ MVC, Design Patterns, RESTful
- មានចំណេះដឹងលើផ្នែកសុវត្ថិភាពសម្រាប់អ៊ិនធឺណិត ( ជាការប្រសើរ )
- មានសមត្ថភាពក្នុងការដោះស្រាយបញ្ហាសុសវែរ (Troubleshooting) ដោយឯករាជ្យ
- មានចំណេះដឹងភាសាអង់គ្លេសច្បាស់លាស់ អាចនិយាយ និងសរសេរជាផ្លូវការបាន។

## ៣. **បុគ្គលិកផ្នែកវិស្វករគ្រប់គ្រងគុណភាព** ( Quality Assurance Engineer )

*ភារកិច្ច និង ការទទួលខុសត្រូវ៖*

- មានសមត្ថភាពអាចធ្វើការជាមួយអ្នកគ្រប់គ្រងគម្រោង អំពីមុខងាររបស់ប្រព័ន្ធ
- រៀបផែនការក្នុងការអនុវត្តសាកល្បងសម្រាប់ការធ្វើ Manual តេស្ត និង Automatic តេស្ត
- រាយការណ៍អំពីលទ្ធផលនៃការធ្វើតេស្ត និង បញ្ហា
- អនុវត្តផែនការសាកល្បងក្នុងការប្រើប្រាស់ឧបករណ៍សាកល្បង

*គុណវុឌ្ឍិ៖*

- មានបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ ព័ត៌មានវិទ្យា ឬ ជំនាញដែលពាក់ព័ន្ធ
- មានបទពិសោធន៍ក្នុងផ្នែកវិស្វករគ្រប់គ្រងគុណភាពយ៉ាងតិច ១ឆ្នាំ
- មានចំណេះដឹងលើ Shell script
- មានចំណេះដឹងលើ RES API និង ប្រព័ន្ធសុវត្ថិភាព
- មានជំនាញភាសាកម្មវិធី JAVA, JS, Groovy ជាដើម
- មានបទពិសោធន៍ក្នុងការប្រើប្រាស់កម្មវិធី ឬ ប្រព័ន្ធ Docker ( ជាការប្រសើរ )
- មានសមត្ថភាពក្នុងការដោះស្រាយបញ្ហា និង ភាពស្មុកស្មាញដោយខ្លួនឯង
- មានសមត្ថភាពក្នុងការធ្វើការងារជាក្រុម និង គាំទ្រផ្នែកបច្ចេកទេសដល់ក្រុមការងារ
- មានចំណេះដឹងភាសាអង់គ្លេសច្បាស់លាស់ អាចនិយាយ និងសរសេរជាផ្លូវការបាន។

## ៤. **បុគ្គលិកផ្នែកអភិវឌ្ឍបណ្តាញកម្មវិធីទូរស័ព្ទ** ( Cross-Platform Mobile App Developer )

*ភារកិច្ច និង ការទទួលខុសត្រូវ៖*

- អភិវឌ្ឍកម្មវិធីសម្រាប់ប្រតិបត្តិការការងារ
- ចូលរួមបំពេញការងារគ្រប់ដំណាក់កាលនៃវដ្តគម្រោង (Agile Project Cycle) រួមមានការរចនា ការបង្កើតគំរូ ការអភិវឌ្ឍន៍ និងការធ្វើតេស្តសាកល្បង តាមរយៈការប្រើប្រាស់កម្មវិធីគ្រប់គ្រងគម្រោង និងប្រើប្រាស់បច្ចេកវិទ្យាចុងក្រោយបំផុត។

- ចូលរួមបំពេញការងារគ្រប់ដំណាក់កាលនៃវដ្តគម្រោង (Agile Project Cycle) រួមមានការរចនា ការបង្កើតគំរូ ការអភិវឌ្ឍន៍ និងការធ្វើតេស្តសាកល្បង តាមរយៈការប្រើប្រាស់កម្មវិធីគ្រប់គ្រងគម្រោង និងប្រើប្រាស់បច្ចេកវិទ្យាចុងក្រោយបំផុត។
- រៀបចំ និងតំឡើងប្រព័ន្ធសុវត្ថិភាព (Encrption and Security) ក្នុងសុសវែរដើម្បីធានានូវប្រសិទ្ធភាព និងសុវត្ថិភាពរបស់ប្រព័ន្ធ
- សហការជាមួយក្រុមការងារអភិវឌ្ឍកម្មវិធី និងអ្នកគ្រប់គ្រងផលិតផល ដើម្បីបង្កើតគំនិត, អភិវឌ្ឍន៍, ធ្វើតេស្ត និងដាក់ចេញឱ្យប្រើប្រាស់
- កែលម្អ ឬអភិវឌ្ឍបន្តកម្មវិធីដែលមានស្រាប់ និង បង្កើតកម្មវិធីថ្មីៗ ដើម្បីពង្រឹងប្រសិទ្ធភាព និង ស័ក្តិសិទ្ធភាព ការងារ
- ស្វែងយល់ និង ស្រាវជ្រាវអំពីនិន្នាការវិវត្តថ្មីនៃបច្ចេកវិទ្យា ដើម្បីអភិវឌ្ឍ និងដោះស្រាយបញ្ហារបស់កម្មវិធីទូរស័ព្ទ

*គុណវុឌ្ឍិះ*

- មានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ ផ្នែកបច្ចេកវិទ្យាព័ត៌មាន ឬ ជំនាញដែលពាក់ព័ន្ធ
- មានបទពិសោធន៍ក្នុងផ្នែកអភិវឌ្ឍបណ្តាញកម្មវិធីទូរស័ព្ទ យ៉ាងតិច ២ឆ្នាំ
- មានចំណេះដឹងក្នុងផ្នែករចនាផ្ទាំងកម្មវិធី (ជាការប្រសើរ)
- សមត្ថភាពយល់ដឹងអំពីប្រព័ន្ធសុវត្ថិភាព
- មានសមត្ថភាពក្នុងការដោះស្រាយបញ្ហា និង ភាពស្ទុកស្មាញដោយខ្លួនឯង
- មានសមត្ថភាពក្នុងការធ្វើការងារជាក្រុម និង គាំទ្រផ្នែកបច្ចេកទេសដល់ក្រុមការងារ
- មានចំណេះដឹងភាសាអង់គ្លេសច្បាស់លាស់ អាចនិយាយ និងសរសេរជាផ្លូវការបាន។

*ចាប់ផ្តើមទទួលពាក្យចាប់ពីថ្ងៃជូនដំណឹងរហូតដល់ថ្ងៃទី២៩ ខែ មិនា ឆ្នាំ ២០២៤ វេលាម៉ោង ១៧:០០នាទី ។*

ថ្ងៃព្រហស្បតិ៍ ៥កើត ខែ ផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែ មិនា ឆ្នាំ២០២៤